ស្ថានទូតអូស្ត្រាលី
ភ្នំពេញ

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍របស់ស្ថានទូតអូស្ត្រាលី
# អំពីវិសោធនកម្មច្បាប់ស្តីអំពីគណបក្សនយោបាយនៅកម្ពុជា

រដ្ឋាភិបាលអូស្ត្រាលីមានសេចក្តីព្រួយបារម្ភចំពោះវិសោធនកម្មនៃច្បាប់ស្តីអំពីគណបក្សនយោបាយនៅកម្ពុជា ដែលបានអនុម័តនាពេលថ្មីៗនេះ។ ក្នុងនាមជាមិត្តភក្តិនិងអ្នកគាំទ្រដ៏យូរអង្វែងដល់ការអភិវឌ្ឍន៍នៅកម្ពុជា អូស្ត្រាលីយល់អំពីសារៈសំខាន់នៃការបោះឆ្នោតដែលគួរឲ្យទុកចិត្តបាន ចំពោះប្រជាជនកម្ពុជាគ្រប់រូប។ ច្បាប់ទាំងឡាយដែលមានការរឹតត្បិតដល់គណបក្សនយោបាយនិងសេរីភាពរបស់ពលរដ្ឋក្នុងការចូលរួមនៅក្នុងដំណើរការនយោបាយ ដោយពុំមានភាពចាំបាច់ណាមួយនោះ គឺជាក្តីបារម្ភ។ អូស្ត្រាលីសូមលើកទឹកចិត្តកម្ពុជាក្នុងការអនុវត្តឲ្យបានទាំងស្រុងនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យដូចដែលបានបញ្ជាក់នៅក្នុងធម្មនុញ្ញអាស៊ាន។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au